**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ...០៩៣...សហវ...ទស

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែ មករា ឆ្នាំ ២០១១

**គោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម**

**កម្មវត្ថុ:** ករណីស្នើសុំគោលការណ៍ថវិកាចំនួន ៩៨៨.០០០,០០ ដុល្លារអាមេរិក សម្រាប់ការបោសសម្អាតមីន និងកាកសំណល់សង្គ្រាម នៅការដ្ឋានគម្រោងអភិវឌ្ឍន៍ស្ទឹងពោធិសាត់ ទំនប់លេខ ៣ និងលេខ ៥ ។
**យោង:** -លិខិតលេខ ៧០៥ ធទឧ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០១០ របស់ក្រសួងធនធានទឹក និងឧតុនិយម ។
-លិខិតលេខ ១៨៣៣ ធទឧ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០១០ របស់ក្រសួងធនធានទឹក និងឧតុនិយម ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមឯកភាពជាគោលការណ៍ធ្វើការធានាចំណាយនូវថវិកាបដិភាគរាជរដ្ឋាភិបាល ជាទឹកប្រាក់ចំនួន ៣.៨៧៩.៣០០.០០០៛០០ (បីពាន់ប្រាំបីរយចិតប្រាំបួនលានបីរយពាន់រៀលគត់) សម្រាប់ការបោសសម្អាតមីន និងកាកសំណល់សង្គ្រាម នៅការដ្ឋានគម្រោងអភិវឌ្ឍន៍ស្ទឹងពោធិសាត់ ទំនប់លេខ ៣ និងលេខ ៥ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាប និងមានវិធានការ តាមការគួរ ។
សូមឯកឧត្តមមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

ចម្លងជូន:
- មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកំលាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com